*Khmer*

## ព័ត៌មានសំរាប់សាធារណជន

## បញ្ជីកម្មវិធីជាតិនៃការចាក់ថ្នាំបង្ការរោគ HPV

### តើកម្មវិធីជាតិនៃការចាក់ថ្នាំបង្ការរោគ HPV ជាអ្វី?

កម្មវិធីជាតិនៃការចាក់ថ្នាំបង្ការរោគសាច់ដុះលើស្បែកមនុស្សដោយមេរោគវីរុស(Human Papillomavirus-HPV) បានចាប់ផ្តើមឡើងក្នុងខែកក្កដាឆ្នាំ 2007។ កម្មវិធីនេះបានទទួលថវិកាផ្គត់ផ្គង់ពីរដ្ឋាភិបាលអូស្រ្តាលី។ កម្មវិធីនេះផ្តល់នូវថ្នាំបង្ការរោគ HPV ដោយឥតគិតថ្លៃដល់ស្រ្តីទាំងឡាយដែលមានសិទ្ធិទទួល ដើម្បីការពារប្រឆាំងនឹងមូលហេតុដែលបណ្តាលឲ្យកើតរោគមហារីកកស្បូនច្រើនជាងគេ។ ថ្នាំបង្ការរោគនេះបានផ្តល់ដោយឥតគិតថ្លៃដល់ ៖

- ក្មេងស្រីដែលមានអាយុ 12ឆ្នាំ និង 13ឆ្នាំ តាមរយៈសាលារៀនក្នុងមូលដ្ឋានជាបន្តបន្ទាប់
- ក្មេងស្រីដែលមានអាយុ 13–18ឆ្នាំដែលនៅរៀន (ដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2009)
- ស្រ្តីដែលមានអាយុ18–26ឆ្នាំ (ដល់ថ្ងៃទី 30 ខែមិថុនា ឆ្នាំ 2009)

ការចាក់ថ្នាំបង្ការរោគចាំបាច់ចំនួនបីម្ជុល  តាមធម្មតា គេចាក់ថ្នាំនេះចប់សព្វគ្រប់ក្នុងរយៈពេល 6 ខែ។

### តើ HPV Register ជាអ្វី?

បញ្ជីកម្មវិធីជាតិនៃការចាក់ថ្នាំបង្ការរោគ HPV (HPV Register) គឺជាមូលដ្ឋានព័ត៌មានសម្ងាត់មួយដែលប្រមូលផ្តុំព័ត៌មានលំអិតស្តីពីការចាក់ថ្នាំបង្ការរោគ HPV ដែលបានធ្វើនៅក្នុងប្រទេសអូស្រ្តាលី។

### ហេតុអ្វីបានជាខ្ញុំ (ឬកូនស្រីខ្ញុំ)ត្រូវចុះនៅក្នុង HPV Register នេះ?

វាមានប្រយោជន៍ចំបងបីចំពោះការមានឈ្មោះនៅក្នុង HPV Register នេះ។

***i) ប័ណ្ណបញ្ជាក់នៃការចាក់ថ្នាំ***

ពេលដែល HPV Register បានទទួលដំណឹងថា អ្នក(ឬកូនស្រីអ្នក)បានទទួលការចាក់ថ្នាំទាំងបីម្ជុលនេះ ហើយនោះអ្នកនឹងត្រូវគេផ្ញើជូននូវប័ណ្ណបញ្ជាក់នៃការចាក់ថ្នាំមួយសំរាប់ទុកជាកំណត់ហេតុរបស់អ្នក។

***ii) ការរំឭក***

HPV Register នេះនឹងផ្ញើជូនអ្នកនូវសេចក្តីថ្លែងមួយដែលនឹងជំរាបអ្នក ប្រសិនបើអ្នក ឬកូនស្រីអ្នកខកខានមិនបានចាក់ថ្នាំមួយម្ជុលនៅក្នុងកម្មវិធីចាក់ថ្នាំបង្ការរោគ HPV ដែលមានមូលដ្ឋាននៅសាលារៀន។

***iii) ការផ្តល់ព័ត៌មានថ្មីបំផុតនៅអនាគតស្តីពីការចាក់ថ្នាំបន្ថែម(boosters)***

ការស្រាវជ្រាវថ្មីៗបង្ហាញថា កម្រិតថ្នាំចាក់បន្ថែម (booster dose) នៃថ្នាំបង្ការរោគ HPV ទំនងជាមិនត្រូវការទេ។ យ៉ាងណាក៏ដោយ ប្រសិនបើការត្រួតពិនិត្យទៅអនាគតប្រសិទ្ធិភាពនៃថ្នាំបង្ការរោគ HPV បង្ហាញថា ការចាក់ថ្នាំបន្ថែមតម្រូវឲ្យមាននោះ   Register នឹងប្រើព័ត៌មានដែលគេរក្សាទុក ដោយខំព្យាយាមទាក់ទងអ្នកដើម្បីផ្តល់ជូនអ្នកនូវឱវាទដ៏សមរម្យ។

**តើ HPV Register មានគុណប្រយោជន៍ដទៃទៀតឬទេ?**

ដូចគ្នានឹងប្រយោជន៍ដែលមានចំពោះអ្នក(ឬកូនស្រីអ្នក) ការចូលរួមក្នុង HPV Register នឹងជួយរដ្ឋាភិបាលត្រួតពិនិត្យរបៀបដែលកម្មវិធីនៃការចាក់ថ្នាំបង្ការរោគHPV មានដំណើរការ ហើយនិងស្ទង់មើលឥទ្ធិពលនៃកម្មវិធីលើរោគមហារីកកស្បូននេះ។

**តើព័ត៌មានអ្វីខ្លះដែលនឹងត្រូវកត់ត្រាទុកក្នុង HPV Register នេះ?**

ព័ត៌មានដែលបានប្រមូលផ្តុំនិងបានរក្សាទុកក្នុង HPV Register អំពីអ្នក(ឬកូនស្រីអ្នក) នឹងរាប់បញ្ចូលទាំង ៖

- ឈ្មោះ ថ្ងៃកំណើត អាសយដ្ឋាន ឋានៈអន្តោគ្រាម ហើយនិងលេខមេឌីឃាររបស់អ្នកដែលទទួលការចាក់ថ្នាំនេះ
- ឈ្មោះនិងអាសយដ្ឋានរបស់មាតាបិតា ឬអាណាព្យាបាល (ប្រសិនបើត្រូវការ)
- ព័ត៌មានលំអិតនៃកម្រិតថ្នាំត្រូវប្រើក្នុងការចាក់ថ្នាំបង្ការរោគនីមួយៗ
- ឈ្មោះនិងអាសយដ្ឋានកន្លែងធ្វើការរបស់វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាយិកាដែលបានផ្តល់ការចាក់ថ្នាំបង្ការរោគនេះ។

**តើ HPV Register នឹងត្រូវប្រមូលផ្តុំព័ត៌មានដោយរបៀបណា?**

ព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគ HPV ដែលបានធ្វើនៅតាមសាលារៀននឹងផ្តល់ដោយរដ្ឋាភិបាលរដ្ឋនិងដែនដីទៅឲ្យHPV Register ជាផ្នែកនៃកម្មវិធីចាក់ថ្នាំបង្ការរោគ។ ព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគដែលបានធ្វើនៅក្នុងសហគមន៍នឹងត្រូវផ្តល់ទៅឲ្យ HPV Register ដោយអ្នកវិជ្ជាជីវៈខាងសុខភាពដែលផ្តល់ការចាក់ថ្នាំបង្ការរោគ។

**តើកំណត់ហេតុនៃការចាក់ថ្នាំបង្ការរោគខ្ញុំ(ឬកំណត់ហេតុនៃការចាក់ថ្នាំបង្ការរោគរបស់កូនស្រីខ្ញុំ)ត្រូវបញ្ជូនទៅ HPV Register ឬទេ?**

ព័ត៌មាននឹងត្រូវផ្តល់ទៅ Register ដោយមានការអនុញ្ញាតយល់ព្រមរបស់បុគ្គល ឬអាណាព្យាបាលរបស់គេតែប៉ុណ្ណោះ។ ប្រសិនបើអ្នកមិនចង់ឲ្យព័ត៌មានលំអិតទាំងនេះផ្ញើទៅ Register ទេនោះ អ្នកត្រូវប្រាប់ករណីនេះនៅពេលចាក់ថ្នាំបង្ការរោគ។ អ្នកអាចដកព័ត៌មានរបស់អ្នកចេញពី Register បានគ្រប់ពេលវេលាដោយលាយលក្ខណ៍អក្សរទៅ Register។

**តើនរណានឹងមានសិទ្ធិមើលព័ត៌មានរបស់ខ្ញុំ?**

ព័ត៌មានដែលរក្សាទុកក្នុង HPV Register នឹងត្រូវបានរក្សាទុកដោយសម្ងាត់ហើយនិងភាពឯកជនរបស់បុគ្គលម្នាក់ៗត្រូវបានការពារដោយច្បាប់។ ស្ថាប័នផ្តល់ការចាក់ថ្នាំបង្ការរោគ ប្រហែលជាទទួលការអនុញ្ញាតឲ្យមើលព័ត៌មានលំអិតរបស់បុគ្គល ប្រសិនបើគេត្រូវការប្រើក្នុងគោលបំណងនៃការថែរក្សាសុខភាព។

ព័ត៌មានដែលពុំអាចគេសំគាល់ដឹង(ដូចជា ព័ត៌មានដែលមិនអាចសំគាល់ដឹងអំពីរូបអ្នកឬកូនស្រីអ្នក)ប្រហែលជាផ្តល់ទៅឲ្យរដ្ឋាភិបាលអូស្ត្រាលី រដ្ឋ ដែនដីហើយនិងអ្នកស្រាវជ្រាវសំរាប់ធ្វើច្បាប់ ឬគោលបំណងស្រាវជ្រាវដោយមានការយល់ព្រមដ៏សមរម្យ។ ពុំមាននរណាម្នាក់នឹងអាចសំគាល់ដឹងអំពីបុគ្គលស្តីពីព័ត៌មានដែលបានផ្តល់ដោយ Register សំរាប់គោលបំណងនេះឡើយ។

ទៅអនាគត ព័ត៌មានផ្ទាល់ខ្លួនហើយនិងព័ត៌មានចាក់ថ្នាំបង្ការរោគដែលរក្សាទុកនៅក្នុងបញ្ជីកម្មវិធីជាតិនៃការចាក់ថ្នាំបង្ការរោគ HPV នឹងត្រូវគេប្រើជាព័ត៌មានយោងយកពីបញ្ជីព័ត៌មាននៃការធ្វើតេស្តកស្បូន និងរោគមហារីកកស្បូនដែលរក្សាទុកដោយរដ្ឋាភិបាលរដ្ឋ និងដែនដីនៅពេលបច្ចុប្បន្ននេះ។ ព័ត៌មានយោងនេះនឹងអនុញ្ញាតឲ្យរដ្ឋាភិបាលត្រួតពិនិត្យប្រសិទ្ធិភាពនៃថ្នាំបង្ការរោគក្នុងការទប់ស្កាត់រោគមហារីកកស្បូន។

**តើខ្ញុំទាក់ទង HPV Register ដោយរបៀបណា?**

លោកអ្នកអាចទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលទំនាក់ទំនង HPV Register តាមលេខ 1800 478 734 (ចន្លោះម៉ោង8ព្រឹក និង ម៉ោង6ល្ងាច ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ និង ម៉ោង 9ព្រឹក ដល់ម៉ោង 2 រសៀល នៅថ្ងៃសៅរ៍ ទូទាំងប្រទេសអូស្ត្រាលី)។ សូមប្រាប់អ្នកទទួលទូរស័ព្ទឲ្យដឹង ប្រសិនបើលោកអ្នកត្រូវការជំនួយអ្នកបកប្រែ ភាសា។

**ចំពោះព័ត៌មានថែមទៀត ហើយនិង សម្ព័ន្ធការដែលទាក់ទិនគ្នាគឺ**

- National HPV Vaccination Program (កម្មវិធីជាតិនៃការចាក់ថ្នាំបង្ការរោគ)
  http://www.health.gov.au/internet/standby/publishing.nsf/Content/general-practitioners
- Immunise Australia Program (កម្មវិធីសំរាប់ធ្វើឲ្យស៊ាំនឹងរោគអូស្ត្រាលី)
  http://www.immunise.health.gov.au/
- National Cervical Screening Program (កម្មវិធីជាតិសំរាប់ពិនិត្យកស្បូន)
  http://www.cancerscreening.gov.au/internet/screening/publishing.nsf/Content/cervical-1lp